ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# ឆ្នាំទី១

# នៃដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

បោះពុម្ពនៅរាជធានីភ្នំពេញ ខែមិគសិរ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨

ត្រូវនឹង ខែធ្នូ ឆ្នាំ២០២៤

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

Royal Government Spokesperson Unit

# មាតិកា


១. មតិស្វាគមន៍

២. សមិទ្ធផលនៃកិច្ចការងារក្នុង និងក្រៅប្រទេស

២.១. កិច្ចការងារក្នុងស្រុក

២.១.១. សន្តិសុខសង្គម

២.១.២. ការលើកកម្ពស់វិស័យសេដ្ឋកិច្ច

២.១.៣. ការកសាងហេដ្ឋារចនាសម្ព័ន្ធចម្បងៗ

២.១.៤. ការអភិវឌ្ឍវិស័យសង្គមកិច្ច

២.២. កិច្ចការងារការបរទេស និងទំនាក់ទំនងអន្តរជាតិ

២.២.១. ពង្រឹងមិត្តភាពចាស់ ពង្រីកមិត្តភាពថ្មី

២.២.២. ការទូតសេដ្ឋកិច្ច

៣. កម្មវិធីគោលនយោបាយអាទិភាពទាំង៦

៤. វិធានការគន្លឹះទាំង៥

៥. សេចក្តីសន្និដ្ឋាន

# ១. មតិស្វាគមន៍



ឯកឧត្តម ប៉ែន បូណា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល (អ.អ.រ.) សូមគោរពស្វាគមន៍យ៉ាងកក់ក្ដៅចំពោះ សម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា និងបងប្អូនជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស ដែលបានចាប់អារម្មណ៍អានរបាយការណ៍សង្ខេបឆ្នាំទី១ នៃដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

តាមរយៈរបាយការណ៍សង្ខេបនេះ អ.អ.រ. មានកិត្តិយសសូមបង្ហាញជូននូវគោលនយោបាយ និងសមិទ្ធផលនានា ចាប់តាំងពីថ្ងៃដំបូង នៃរាជរដ្ឋាភិបាលបន្តវេន ដឹកនាំដោយ សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរួមមាន ការប្ដេជ្ញាចិត្តរក្សាឱ្យបានគង់វង្ស និងពង្រឹងឱ្យកាន់តែរឹងមាំនូវសមិទ្ធផលនានា ដែលកសាងដោយរាជរដ្ឋាភិបាលអាណត្តិមុនៗ ដឹកនាំដោយ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងការប្ដេជ្ញាចិត្តកសាងសមិទ្ធផលថ្មីៗ ជូនជាតិមាតុភូមិតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាពទាំង៦ ជាមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់។

ក្នុងរយៈពេលដែលរាជរដ្ឋាភិបាលបន្តវេនឡើងកាន់តំណែងរហូតមកដល់ចុងឆ្នាំ២០២៤ នេះ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** និងមន្ត្រីក្រោមឱវាទគ្រប់ជាន់ថ្នាក់ បានខិតខំប្រឹងប្រែងប្រែក្លាយគោលនយោបាយនានាជាសកម្មភាពជាក់ស្ដែង និងសម្រេចបាននូវលទ្ធផលលេចធ្លោជាច្រើន ក្នុងចំណោមនោះ មានការធ្វើកំណែទម្រង់លើវិស័យធំៗដូចជា រដ្ឋបាលសាធារណៈ សេដ្ឋកិច្ច សុខាភិបាល អប់រំ កសិកម្ម ព្រមទាំងលើកកម្ពស់ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ និងការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់អភិវឌ្ឍន៍លើគ្រប់វិស័យ។

ឆ្លៀតក្នុងឱកាសនេះ អ.អ.រ. សូមថ្លែងអំណរគុណ ឯកឧត្តម **តាន់ ហ្សង់ហ្វ្រង់ស័រ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអ្នកនាំពាក្យនៃក្រសួងពាក់ព័ន្ធនានា ចំពោះកិច្ចសហការដ៏សកម្មក្នុងការផ្ដល់ព័ត៌មានលើកិច្ចការងារជាតិ និងអន្តរជាតិបានយ៉ាងពិស្ដារ និងគ្រប់ជ្រុងជ្រោយ។

ជាទីបញ្ចប់ ជូសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល សូមសម្តែងនូវសេចក្តីគោរព និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនថ្នាក់ដឹកនាំគ្រប់រូប មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ព្រមទាំងជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស រួមទាំងដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធទាំងអស់ ដែលបាន និងបន្តចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ហើយបានផ្តល់ជំនឿ និងការគាំទ្រដ៏ធំធេង ចំពោះរាជរដ្ឋាភិបាលនៅគ្រប់ដំណាក់កាល៕

រាជធានីភ្នំពេញ ខែមិគសិរ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨
ត្រូវនឹង ខែធ្នូ ឆ្នាំ២០២៤

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

ប៉ែន បូណា

# ២. សមិទ្ធផលនៃកិច្ចការខាងក្នុង និងក្រៅប្រទេស

## ២.១ កិច្ចការខាងក្នុងស្រុក

### ២.១.១. សន្តិសុខសង្គម



រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានបន្តជំហរដាច់ខាត មុឹងម៉ាត់ក្នុងការរក្សាសន្តិភាព ការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ដោយពង្រឹងការឯកភាពជាតិ សំដៅទប់ស្កាត់ និងលុបបំបាត់នូវរាល់នយោបាយនិងសកម្មភាពជ្រុលនិយម បង្កឡើងដោយបុគ្គល ក្រុមពួក ឬ អង្គការចាត់តាំងនយោបាយណាមួយ ឬមជ្ឈដ្ឋានអមិត្តផ្សេងៗ ដែលព្យាយាមញុះញង់បង្កការបែកបាក់ជាតិ។

សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី និង សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីបន្តវេន បានបង្ហាញជំហរដ៏រឹងមាំ គឺមិនយកអធិបតេយ្យភាពជាតិទៅដោះដូរជាមួយជំនួយបរទេស ឬភាពអនុគ្រោះណាមួយជាដាច់ខាត។ ចំពោះកិច្ចការពារអធិបតេយ្យភាពជាតិ បូរណភាពទឹកដី ទាំងអតីតប្រមុខរាជរដ្ឋាភិបាល និងប្រមុខរាជរដ្ឋាភិបាលបន្តវេន បានប្តេជ្ញាយ៉ាងមុឹងម៉ាត់ គឺមិនអនុញ្ញាតឱ្យបាត់បង់ទឹកដីសូម្បីតែមួយមីលីម៉ែត្រ។ ជាឧទាហរណ៍ជាក់ស្តែងមួយក្នុងចំណោមការងារជាក់ស្តែងរាប់មិនអស់ រាជរដ្ឋាភិបាលបានបន្តការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការកសាងផ្លូវក្រវាត់ព្រំដែន ការរៀបចំតំបន់រស់នៅជូនប្រជាពលរដ្ឋដែលខ្វះដីធ្លី អាចទៅរស់នៅតំបន់ព្រំដែន ការជំរុញនិងការការពារធនធានធម្មជាតិនៅតំបន់នោះ និងការដាក់ចេញនូវកញ្ចប់លើកទឹកចិត្តវិនិយោគនៅតាមព្រំដែនជាដើម។ បន្ថែមលើនេះ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានអនុញ្ញាតឱ្យរៀបចំដំណើរទស្សនកិច្ចតាមផ្លូវក្រវាត់ព្រំដែនរៀងរាល់ចុងសប្តាហ៍ ជូនដល់ប្រជាពលរដ្ឋបានចូលរួមដោយសេរី ក្រោមគោលការណ៍អ្នកចុះឈ្មោះមុនបានមុន ដែលដំណើរទស្សនកិច្ចនេះ បានចាប់ផ្តើមនៅខែកញ្ញា និងបញ្ចប់នៅចុងខែធ្នូ





ឆ្នាំ២០២៤។ តាមរយៈដំណើរទស្សនកិច្ចនេះ ប្រជាពលរដ្ឋនិងយុវជនដែលបានចូលរួមសុទ្ធតែសម្តែងការសប្បាយរីករាយ និងបានយល់ច្បាស់ពីការងារព្រំដែន ហើយជឿជាក់ទាំងស្រុងដោយគ្មានមន្ទិលសង្ស័យអ្វីទាំងអស់ចំពោះរឿងព្រំដែននេះ។

### ២.១.២. ការលើកកម្ពស់វិស័យសេដ្ឋកិច្ច

រាជរដ្ឋាភិបាលបន្តវេនដឹកនាំដោយ សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ បាននិងបន្តខិតខំដោះស្រាយនូវបញ្ហាប្រឈមនានា ដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់ក្នុងការអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច និងបង្កើនកិច្ចការងារបុរេសកម្មដើម្បីឈានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់ ដូចដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ជាមួយនឹងកិច្ចប្រឹងប្រែងប្រកបដោយភាពបុរេសកម្ម សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថា អាចសម្រេចបានកំណើនក្នុងរង្វង់ប្រមាណ ៦% នៅឆ្នាំ២០២៤ និងត្រូវបានព្យាករថា នឹងបន្តកើនឡើងក្នុងរង្វង់ប្រមាណ ៦,៣% នៅឆ្នាំ២០២៥។

ក. លទ្ធផលការងារពាណិជ្ជកម្ម ក្នុងរយៈពេល ១១ខែ ក្នុងឆ្នាំ២០២៤ បានកើនឡើងប្រមាណ ១៥,៩៥% ក្នុងទំហំទឹកប្រាក់ប្រមាណ ៥០,៤៦ប៊ីលានដុល្លារ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។ ការនាំចេញមានកំណើន ១៤,៣៦% ក្នុងទំហំទឹកប្រាក់ប្រមាណជាង ២៤,៣៤ប៊ីលានដុល្លារ ទៅកាន់ទីផ្សារធំៗ មានដូចជា អាស៊ាន សហភាពអឺរ៉ុប សហរដ្ឋអាម៉េរិក ចិន ជប៉ុន និង កាណាដា។ ចំណែកការនាំចូល កើនឡើង ១៧,៤៨% គិតជាទឹកប្រាក់ប្រមាណជាង ២៦,១ប៊ីលានដុល្លារ។




សម្រាប់វិស័យឧស្សាហកម្ម ចំនួនរោងចក្រ (ធុនធំ) គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ មានចំនួនសរុប ២ ៣៥៧ ពោលគឺកើនឡើងចំនួន ២៣២ រោងចក្រ ស្មើនឹងប្រមាណ ១១% ធៀបនឹងចំនួនរោងចក្រសរុបនៅឆ្នាំ ២០២៣។ ក្នុងនោះ ទុនវិនិយោគសរុបគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ នេះ មានចំនួនប្រមាណ ២០ពាន់លានដុល្លារ ដែលបរិមាណនេះមានការកើនឡើងចំនួន ១១,៥៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣។ ជាមួយនឹងចំនួនរោងចក្រ និងទុនវិនិយោគខាងលើនេះ តម្លៃបរិមាណផលិតផលសរុប គិតត្រឹមខែតុលា ឆ្នាំ២០២៤ មានចំនួនជាង ៨២១,៩លានដុល្លារ (ក្នុងនោះតម្លៃ

បរិមាណផលិតផលសម្រាប់បម្រើទីផ្សារក្នុងស្រុក មានចំនួនជាង ២៦៨លានដុល្លារ និងសម្រាប់នាំចេញ មានចំនួនជាង ៥៥៣,៩លានដុល្លារ)។

**ការនាំចេញផលិតផលកសិកម្ម** ក្នុងរយៈពេល ១១ខែ ក្នុងឆ្នាំ២០២៤ មានទំហំទឹកប្រាក់ប្រមាណជាង ៣,៦ប៊ីលានដុល្លារ ក្នុងបរិមាណសរុបចំនួនប្រមាណជាង ១០,៤លានតោន កើនឡើង ៤២,៣២% ធៀបក្នុងរយៈពេលដូចគ្នាឆ្នាំ២០២៣។ ផលិតផលកសិកម្មដែលនាំចេញទាំងនោះរួមមាន ស្រូវ អង្ករ និងកសិផលក្រៅពីស្រូវ-អង្ករ មាន ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី ស្វាយកែវរមៀត ជ័រកៅស៊ូ ចេក ពោត និងទំនិញផ្សេងៗទៀត។

**ខ. ការវិនិយោគដោយវិនិយោគិនក្នុង និងក្រៅស្រុក** ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តគម្រោងវិនិយោគថ្មី និងគម្រោងពង្រីកផលិតកម្មសរុបចំនួន ៣៨៩ ក្នុងទុនវិនិយោគប្រមាណ ៦,៥ពាន់លានដុល្លារ កើនឡើងប្រមាណ ៤០% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ដោយបង្កើតការងារបានចំនួនប្រមាណ ៣០០ ០០០ កន្លែង ថែមទៀត។ ក្នុងចំណោមគម្រោងវិនិយោគទាំង ៣៨៩នេះ មានគម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៩គម្រោង ក្នុងទុនវិនិយោគប្រមាណ ៦៥០ លានដុល្លារ។ សកម្មភាពវិនិយោគទាំងនេះត្រូវបានបែងចែកតាមវិស័យ ដូចខាងក្រោម៖



១. វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម មានចំនួន ៨គម្រោង ក្នុងទុនវិនិយោគប្រមាណជាង ១២០លានដុល្លារ។
២. វិស័យឧស្សាហកម្ម មាន ៣៧០គម្រោង ក្នុងទុនវិនិយោគប្រមាណ ៤,៤ប៊ីលានដុល្លារ។
៣. វិស័យទេសចរណ៍ មាន ៤គម្រោង ក្នុងទុនវិនិយោគប្រមាណ ៧៣៩លានដុល្លារ។
៤. វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ មាន ៧គម្រោង ក្នុងទុនវិនិយោគប្រមាណ ១,២ ប៊ីលានដុល្លារ។

**គ. វិស័យការងារ** រាជរដ្ឋាភិបាលតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តែងតែគិតគូរយកចិត្តទុកដាក់ជាពិសេសលើសុខទុក្ខរបស់បងប្អូនកម្មករនិយោជិតទាំងការធ្វើការងារនៅតាមរោងចក្រ សហគ្រាស និងការផ្តល់ប្រព័ន្ធគាំពារសង្គម និងជីវភាពរស់នៅ សំដៅប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានជួយសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធគ្រប់ភាគីដើម្បីធានាថា កម្មករ-និយោជិត ទទួលប្រាក់ឈ្នួលប្រសើរជាងមុន។ ជាលទ្ធផលកម្មករ-និយោជិត

បានទទួលប្រាក់ឈ្នួលអប្បបរមា ២០៤ដុល្លារ ក្នុងមួយខែ នៅក្នុងឆ្នាំ២០២៤ ដែលប្រាក់ឈ្នួលមធ្យមទាបបំផុតគឺស្ថិតក្នុងចន្លោះពី ២២១ ទៅ ២៣២ដុល្លារក្នុងមួយខែ។

ចំពោះការគាំទ្រដល់ពលករកម្ពុជាធ្វើការនៅបរទេស រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើនដើម្បីការពារផលប្រយោជន៍ពលករខ្មែរនៅក្រៅប្រទេស៖

- អាជ្ញាធរថៃបានឯកភាពកាត់បន្ថយតម្លៃទិដ្ឋាការការងារពី ២ ០០០បាត មកនៅត្រឹម ៥០០ បាត និងបន្ថយតម្លៃពន្យារសុពលភាពទិដ្ឋាការការងារពី ១ ៩០០បាត មកនៅត្រឹម ៥០០បាត សម្រាប់រយៈពេល ៤ឆ្នាំ (ពីខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ខែវិច្ឆិកា ឆ្នាំ២០២៧)



- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអនុស្សរណៈជាមួយធនាគារធំៗ ចំនួន ៨ សម្រាប់ពលករ ចេញទៅធ្វើការក្រៅប្រទេស អាចខ្ចីប្រាក់រហូតដល់ ៥ ០០០ដុល្លារ និងផ្តល់ប្រាក់កម្ចីមានអត្រាការប្រាក់ទាបត្រឹមកម្រិត ៨,៥% ក្នុងមួយឆ្នាំ ឬ ប្រហែល ០,៧១% ក្នុងមួយខែ ដោយអាចជួយសម្រាលបន្ទុកដល់បងប្អូនពលករបាន ១០% ជាមធ្យមក្នុង១ឆ្នាំ។

ឃ. វិស័យទេសចរណ៍ រាជរដ្ឋាភិបាលបន្តវេនបានដាក់ចេញនូវវិធានការអន្តរាគមន៍នានាជាបន្តបន្ទាប់ ដើម្បីស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ដោយផ្តោតលើ ៣ ដំណាក់កាល៖ ទី១ ភាពធន់នៃទេសចរណ៍ ទី២ ការងើបឡើងវិញនៃវិស័យទេសចរណ៍ និងទី៣ ដំណើរការឡើងវិញឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា។ បច្ចុប្បន្ន កម្ពុជាបានទទួលនូវកំណើនភ្ញៀវទេសចរអន្តរជាតិជាបណ្តើរៗ ជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ ភ្ញៀវអន្តរជាតិមកកម្ពុជាមានប្រមាណ ៦លាននាក់ កើនឡើងចំនួន ២២% ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ដោយភាគច្រើនមកពីប្រទេសជាសមាជិកអាស៊ាន ចិន សហរដ្ឋអាមេរិក កូរ៉េខាងត្បូង អង់គ្លេស ជប៉ុន អូស្ត្រាលី ឥណ្ឌា និងសហភាពអឺរ៉ុប។

### ២.១.៣. ការកសាងហេដ្ឋារចនាសម្ព័ន្ធចម្បងៗ

រាជរដ្ឋាភិបាលបានបញ្ចប់គម្រោងគមនាគមន៍សំខាន់ៗជាច្រើន ដូចជា អាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ និងកំពង់ផែពហុបំណងកំពត ហើយបាននិងកំពុងបន្តសាងសង់ហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជា ព្រែកជីកហ្វូណនតេជោ អាកាសយានដ្ឋានអន្តរជាតិតេជោ ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងបាវិត ការពង្រីកសមត្ថភាពកំពង់ផែទឹកជ្រៅខេត្តព្រះសីហនុ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ និងបណ្តាញលូគ្រប់ប្រភេទ ព្រមទាំងស្ពានអាកាស និងស្ពានឆ្លងកាត់ទន្លេមួយចំនួនទៀតនៅរាជធានី



ភ្នំពេញ និងបណ្តាខេត្ត។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល បានបន្តជំរុញកសាង ជួសជុល ថែទាំ និងកែលម្អផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំ ផ្លូវជនបទ និងផ្លូវក្រវាត់ព្រំដែន។ សម្រាប់ការកសាងប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធរំដោះទឹក រួមមានគម្រោងសំខាន់ៗដូចជា៖

- អាងទឹកដងកាំបិត នៅខេត្តព្រះវិហារ និងកំពង់ធំ មានលទ្ធភាពស្រោចស្រពផ្ទៃដីជាង ១៣០ ០០០ហិកតា
-អភិវឌ្ឍន៍អាងទំនប់ទឹកដូនទ្រី នៅខេត្តបាត់ដំបង មានលទ្ធភាពស្រោចស្រពផ្ទៃដីជាង ៣០ ០០០ ហិកតា
- អភិវឌ្ឍន៍ធនធានទឹកស្វាហាប់ នៅខេត្តកំពង់ស្ពឺ មានលទ្ធភាពស្រោចស្រពផ្ទៃដីទំហំប្រមាណ ២៦ ០០០ហិចតា ក្នុងរដូវវស្សា និង ១០ ០០០ហិចតា ក្នុងរដូវប្រាំង
- អាងស្តុកទឹកស្ទឹងឃ្លៀច នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដើម្បីកាត់បន្ថយទឹកជំនន់ស្ទឹងព្រែកត្នោត និងបរិមាណទឹកទុក ១២៥លានម៉ែតគូប
- ប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ស្ទឹងព្រែកត្នោត នៅខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តតាកែវ មានលទ្ធភាពស្រោចស្រពផ្ទៃដីជិត ៣០ ០០០ ហិកតា
- ប្រព័ន្ធរំដោះទឹកសម្រាប់បញ្ជៀសការជន់លិចក្នុងភូមិសាស្ត្រ រាជធានីភ្នំពេញ ឆ្លងកាត់និងគ្របដណ្តប់ រាជធានីភ្នំពេញ កំពង់ស្ពឺ កណ្តាល និងតាកែវ ដែលការពារមិនឱ្យមានការជន់លិចលើផ្ទៃដី ចំនួន ៣០០ ០០០ហិកតា និងមានលទ្ធភាពស្រោចស្រពផ្ទៃដីប្រមាណ ៥០០ ០០០ ហិកតា




- ប្រព័ន្ធទំនប់អូរតេ នៅខេត្តមណ្ឌលគិរី មានលទ្ធភាពស្រោចស្រពផ្ទៃដី ប្រមាណ ១០ ០០០ហិកតា និងការផ្គត់ផ្គង់ទឹកស្អាតបានរហូតដល់ ១៥ ០០០ម៉ែត្រគូប ក្នុងមួយថ្ងៃ។

### ២.១.៤. ការអភិវឌ្ឍវិស័យសង្គមកិច្ច

រាជរដ្ឋាភិបាលបានផ្តល់សារសំខាន់ចំពោះការលើកកម្ពស់ជីវភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ រួមទាំងមន្ត្រីរាជការ តាមរយៈក្រសួងស្ថាប័នពាក់ព័ន្ធ រួមមាន ក្រសួងមុខងារសាធារណៈ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានសម្រាប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ពី ២ ៥០០ រៀល ទៅ ២ ៦៣០រៀល ក្នុងមួយសន្ទស្សន៍ (បានអនុវត្តចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤)
- ដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យាពី ៧១០ ០០០រៀល ទៅ ៧៧០ ០០០រៀល (បានអនុវត្តចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤)
- ប្រាក់កម្រៃឧបត្ថម្ភប្រចាំខែជូនគរុសិស្ស គរុនិស្សិត និងសិស្សមន្ត្រីប្រឡងជាប់ក្នុងពេលបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ត្រូវបានកំណត់យក ៧០% នៃបៀវត្សរ៍សរុប។ ជាលទ្ធផល៖
    - ក្របខ័ណ្ឌ ក កើនពី ៦០៣ ៧៥០ រៀល ទៅ ១ ១៨១ ១៤៥ រៀល/ខែ
    - ក្របខ័ណ្ឌ ខ កើនពី ៥៦២ ៥០០ រៀល ទៅ ១ ០៩១ ៣០០ រៀល/ខែ
    - ក្របខ័ណ្ឌ គ កើនពី ៥៣០ ០០០ រៀល ទៅ ១ ០១៩ ៨៦៥ រៀល/ខែ (បានអនុវត្តចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤)
- ដំឡើងបន្ថែមប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ចន្លោះពី ២០ ០០០ ទៅ ២៥ ០០០រៀល តាមកម្រិត (បានអនុវត្តចាប់តាំងពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤)
- ដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចន្លោះពី ៤០ ០០០រៀល ទៅ ៨០ ០០០រៀល (បានអនុវត្តចាប់តាំងពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤)
- របបសន្តិសុខសង្គមប្រចាំខែរបស់មន្ត្រីចូលនិវត្តន៍ និងអតីតយុទ្ធជន កើនពី ៧៧០ ០០០រៀល ទៅ ៨២៥ ០០០រៀល (បានអនុវត្តចាប់តាំងពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤)




- ឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលជា សមាជិក ប.ស.ស. សរុបចំនួនជាង ១២៤ពាន់នាក់ និងកូនចំនួនសរុបជាង ១០៤ពាន់នាក់ ដោយចំណាយថវិកាចំនួនជិត ១០២ពាន់លានរៀល (ស្មើនឹង ជាង ២៥លានដុល្លារ)។

## ២.២ កិច្ចការងារការបរទេស និងទំនាក់ទំនងអន្តរជាតិ

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលដែលសម្តេចឡើងកាន់តំណែងរហូតមកដល់ចុងឆ្នាំ២០២៤ នេះ បានធ្វើដំណើរឆ្លងកាត់ទ្វីបទាំង៥ នៃពិភពលោក (អាស៊ី អាម៉េរិក អាហ្វ្រិក អឺរ៉ុប និងអូសេអានី) និងប្រទេសចំនួន ១៧។ សម្រាប់ក្នុងប្រទេស **សម្តេចធិបតី** បានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះថ្នាក់ដឹកនាំប្រតិភូបរទេសមកពីបណ្តាប្រទេសជាច្រើន។ ទន្ទឹមនឹងនេះ **សម្តេចធិបតី** បានចូលរួមកិច្ចប្រជុំ និងដំណើរទស្សនកិច្ចក្រៅប្រទេសយ៉ាងសកម្ម ក្នុងគោលបំណងធំៗចំនួនពីរ គឺការពង្រឹងមិត្តភាពចាស់ ពង្រីកមិត្តភាពថ្មី និងការទូតសេដ្ឋកិច្ច។ ការទូតដែលមានមុខព្រួញ ២ ទន្ទឹមគ្នានេះ មានគោលដៅច្បាស់លាស់ នោះគឺធ្វើឱ្យសហគមន៍អន្តរជាតិបង្កើនក្តីគោរពចំពោះកម្ពុជាដែលជារដ្ឋអធិបតេយ្យមួយពេញលក្ខណៈ និងស្វែងរកប្រយោជន៍សេដ្ឋកិច្ចជាពិសេសមកជូនប្រជាជាតិកម្ពុជាទាំងអស់គ្នា។



### ២.២.១.ពង្រឹងមិត្តភាពចាស់ ពង្រីកមិត្តភាពថ្មី

ឈរលើគោលជំហរការទូតពង្រឹងមិត្តភាពចាស់ និងពង្រីកមិត្តភាពថ្មីនេះ មានគោលដៅជាសារវន្តមួយចំនួន នោះគឺបន្តការពារជំហរផ្លូវការរបស់កម្ពុជានៅលើឆាកអន្តរជាតិ បន្តរក្សាសន្តិភាព បន្តការពារយ៉ាងស្វិតស្វាញឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងបន្តជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៃប្រទេសកម្ពុជាតទៅទៀត។




ក្នុងកិច្ចការងារនេះ **សម្តេចធិបតី** បានទទួលស្វាគមន៍ប្រទេសជាមិត្ត រួមមាន ចិន អាម៉េរិក បារាំង វៀតណាម ថៃ ឡាវ ។ល។ ខាងក្រោមជាឧទាហរណ៍ជាក់ស្តែងមួយចំនួននៃកិច្ចការងារពង្រឹងមិត្តភាពចាស់៖

- ជាមួយចិន ទំនាក់ទំនងមិត្តភាពដែកថែបនិងសហប្រតិបត្តិការត្បូងពេជ្រត្រូវបានពង្រឹងនៅ

ក្នុងក្របខ័ណ្ឌនៃការកសាងសហគមន៍វាសនារួម កម្ពុជា-ចិន ក្នុងយុគសម័យថ្មី ២០២៤-២០២៨។ តាមរយៈជំនួបនេះ ប្រទេសចិន បានបង្ហាញនូវការប្តេជ្ញាចិត្តបន្តគាំទ្រដល់មាគ៌ាអភិវឌ្ឍស្របទៅតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា ហើយរដ្ឋាភិបាលចិននឹងបន្តលើកទឹកចិត្តវិនិយោគិនចិន មកកម្ពុជាបន្ថែមទៀត។ ភាគីចិននឹងធ្វើការឱ្យកាន់តែជិតស្និទ្ធថែមទៀតជាមួយកម្ពុជា ដើម្បីកសាងផែនការមេសម្រាប់ច្រករបៀងមច្ឆានិងអង្ករ ច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា ជាមួយនឹងការប្តេជ្ញាចិត្តជំរុញការនាំចូលផលិតផលកសិកម្មកម្ពុជាបន្ថែមទៀត មកកាន់ទីផ្សារចិន។



- ជាមួយបារាំង បន្ថែមលើទំនាក់ទំនងជាប្រវត្តិសាស្ត្រនិងប្រកបដោយផ្លែផ្កាលើវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ ភាសា និងអន្តរកាលថាមពល បារាំង-កម្ពុជាបានឯកភាពលើកកម្ពស់ ទំនាក់ទំនងទ្វេភាគីក្នុងគោលដៅធ្វើឱ្យសម្រេចបាននូវភាពជាដៃគូយុទ្ធសាស្ត្រ ដើម្បីឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែមានភាពស៊ីជម្រៅ។ ជាឧទាហរណ៍ជាក់ស្តែង កម្ពុជា-បារាំង សម្រេចពង្រឹងបន្ថែមនូវទំនាក់ទំនងវប្បធម៌ និងភាសានៅក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិនៃបណ្តាប្រទេសនិយាយភាសាបារាំង (OIF, Organisation Internationale de la Francophonie) កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី នៅឆ្នាំ២០២៦។

- ជាមួយជប៉ុន ទំនាក់ទំនងត្រូវបានដំឡើងកម្រិតឈានដល់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។
- ជាមួយកូរ៉េខាងត្បូង ទំនាក់ទំនងឈានដល់ភាពជាដៃគូយុទ្ធសាស្ត្រ។
- ជាមួយថៃ ទំនាក់ទំនងត្រូវបានដំឡើងកម្រិតឈានដល់ភាពជាដៃគូយុទ្ធសាស្ត្រ។
- ជាមួយឡាវ ទំនាក់ទំនងត្រូវបានដំឡើងកម្រិតឱ្យទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។

រីឯក្នុងគោលដៅពង្រីកមិត្តភាពថ្មីវិញ ចុងក្រោយនេះ កម្ពុជាបានផ្តើមនិងកំពុងបន្តបង្កើត ឬធ្វើឱ្យស្និទ្ធស្នាលនិងស៊ីជម្រៅទំនាក់ទំនងជាមួយបណ្តាប្រទេសមួយចំនួនថែមទៀត រួមមាន៖

- ជាមួយកោះឃុក (Cook Island)
- ជាមួយអារ៉ាប់ប៊ីសាអូឌីត និង
- ជាមួយប្រេស៊ីល ។ល។និង។ល។

## ២.២.២. ការទូតសេដ្ឋកិច្ច

ការទូតសេដ្ឋកិច្ច គឺជាការស្វែងរកប្រយោជន៍សេដ្ឋកិច្ចតាមរយៈការប្រើប្រាស់មធ្យោបាយការទូត និងជាកម្លាំងចលករដ៏ខ្លាំងក្លាមួយក្នុងការចូលរួមក្នុងបេសកកម្មសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។




ដើម្បីសម្រេចគោលដៅនេះ ក្នុងរយៈពេលដែល **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ឡើងកាន់តំណែង រហូតមកដល់ចុងឆ្នាំ២០២៤នេះ សម្តេចមានជំនួបកំពូលទ្វេភាគីជាមួយបណ្តាប្រទេសជាដៃគូជាច្រើន ទាំងតូច មធ្យម និងធំ ទាំងក្នុងនិងក្រៅប្រទេស សុទ្ធសឹងជាឱកាសដើម្បីចរចា ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ ពិសេសកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម។ បន្ថែមលើជំនួបទ្វេនិងពហុភាគីថ្នាក់ប្រមុខរដ្ឋ **សម្តេចធិបតី** មានជំនួបរវាងរដ្ឋនិងវិស័យឯកជនជាច្រើន។ ខាងក្រោមជាឧទាហរណ៍ជាក់ស្តែងមួយចំនួនដែល **សម្តេចធិបតី** ចូលរួមដោយផ្ទាល់៖

- កិច្ចប្រជុំធុរកិច្ចអាស៊ាននៅហ្សាការតា ( ASEAN Business and Investment Summit )
- កិច្ចប្រជុំធុរកិច្ចក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអាសិបលើកទី៣ ( The 3rd RCEP Economic and Trade Cooperation Business Summit ) នៅណាននីង ប្រទេសចិន
- វេទិកាធុរកិច្ចសហរដ្ឋអាម៉េរិក-កម្ពុជា នៅញូវយ៉ក សហរដ្ឋអាម៉េរិក
- វេទិកាសេដ្ឋកិច្ចពិភពលោក ( World Economic Forum ) នៅ Davos ប្រទេសស្វីស
- វេទិកាធុរកិច្ចបារាំង-កម្ពុជា នៅប៉ារីស ប្រទេសបារាំង ដែលរៀបចំឡើងរួមគ្នាដោយសហព័ន្ធនិយោជកបារាំងអន្តរជាតិ ( MEDEF ) និងសភាពាណិជ្ជកម្មកម្ពុជា
- ជំនួបរវាងរដ្ឋនិងវិស័យឯកជនកម្ពុជា ឬ រវាងរដ្ឋនិងវិស័យឯកជនបរទេស ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា៖
  - \+ សភាពាណិជ្ជកម្មកម្ពុជានៅទីក្រុង Montreal ប្រទេសកាណាដា
  - \+ ក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន
  - \+ អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន JETRO
  - +គណៈកម្មាធិការកិច្ចសហប្រតិបត្តិការធុរកិច្ច មេគង្គ-ជប៉ុន នៃសភាពាណិជ្ជកម្មនិងឧស្សាហកម្មជប៉ុន
  - \+ សភាពាណិជ្ជកម្មចិនប្រចាំនៅហុងកុង ។ល។និង។ល។

សកម្មភាពយ៉ាងសកម្មខាងលើ សុទ្ធសឹងជាឱកាសសម្រាប់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ធ្វើការបញ្ចុះបញ្ចូលឱ្យធុរជន និងវិនិយោគិនបរទេសបង្កើនទុន ឬ មកដាក់ទុនវិនិយោគនៅកម្ពុជា។

ជាលទ្ធផលជាក់ស្តែងនៃបេសកកម្មពង្រឹងមិត្តភាពចាស់ ពង្រីកមិត្តភាពថ្មី និងការទូតសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា បានផ្តើមលេចចេញជារូបរាងបណ្តើរៗហើយ ។ ជាក់ស្តែង បារាំងដែលជាប្រទេសដៃគូប្រពៃណីរបស់កម្ពុជា សម្រេចបង្កើនជំនួយអភិវឌ្ឍន៍ដល់កម្ពុជា តាំងពីឆ្នាំ១៩៩៣ មកបារាំងតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ផ្តល់ជាមធ្យមភាគប្រមាណជាង ១០០លានដុល្លារ ក្នុងមួយឆ្នាំៗដល់កម្ពុជា។ តួលេខនេះកើនដល់ ៤៣៥លានដុល្លារ សម្រាប់ឆ្នាំ២០២៣-២០២៤។ ចំពោះការទាក់ទាញអ្នកវិនិយោគក្នុងរយៈពេល១១ខែ ឆ្នាំ២០២៤ គម្រោងវិនិយោគបានកើនឡើងប្រមាណ ៤០% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។

## ៣. កម្មវិធីគោលនយោបាយអាទិភាពទាំង៦

កម្មវិធីគោលនយោបាយអាទិភាពទាំង៦ ត្រូវបានប្រកាសឱ្យអនុវត្តជាបន្ទាន់ដោយ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នៅពេលដែល សម្តេច ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីភ្លាម ដើម្បីគាំពារប្រជាពលរដ្ឋក្រីក្រ និងងាយរងហានិភ័យ ដែលមានចំណូលទាប ឱ្យពួកគាត់មានចំណូលខ្ពស់ដែលជាកម្លាំងចលករជួយរុញច្រាននាវាកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

### ៣.១. ផ្តល់ការថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់ជាសកល

តាមរយៈគោលនយោបាយនេះ ប្រជាពលរដ្ឋទទួលបានបណ្ណមូលនិធិសមធម៌សុខាភិបាលបានកើនដល់ជាង ៤,៧លាននាក់ រួមមាន គ្រួសារងាយរងហានិភ័យ គ្រួសារក្រីក្រ (ក្រ១ និងក្រ២)



កម្មករ-និយោជិតក្រៅប្រព័ន្ធ មេភូមិ អនុភូមិ ជំនួយការភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ កីឡាករ កីឡាការិនី បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ សមាគមម៉ូតូរ៉ឺម៉កកង់បី អ្នកធាក់ស៊ីក្លូ បុគ្គលិក និងអ្នកជំនាញដោះមីននៃប្រតិបត្តិករបោសសម្អាតមីន។

ជាមួយគ្នានេះ គិតត្រឹមពាក់កណ្តាលខែធ្នូ ឆ្នាំ២០២៤ នេះ អ្នកទទួលបានប័ណ្ណ ប.ស.ស. បច្ចុប្បន្នមានរហូតដល់ទៅជាង ២,៨លាននាក់ ក្នុងនោះមានផ្នែកកម្មករនិយោជិត

ចំនួនជាង ១,៧លាននាក់ មន្ត្រីរាជការសាធារណៈ មន្ត្រីចូលនិវត្តន៍ និងអតីតយុទ្ធជនមានចំនួន ៤៩៣ ៧៣៧នាក់ និងបុគ្គលស្វ័យនិយោជន៍មានចំនួន ៤៥៨ ០៧៩នាក់ និងអ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស.មានចំនួន ១៤៥ ១៩១នាក់។

### ៣.២. បណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដល់កូនអ្នកក្រីក្រ និងងាយរងហានិភ័យ

គោលនយោបាយនេះ កសាងឡើងដើម្បីគាំទ្រយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេសចំនួន ១,៥លាននាក់ ឱ្យទទួលបាននូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ



និងបច្ចេកទេសច្បាស់លាស់ដោយមិនបង់ថ្លៃសិក្សាក្នុងរយៈពេល ៤ខែ និងទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលសរុប ១,១២លានរៀល (ពោលគឺចំនួន ២៨០ ០០០រៀល ក្នុងមួយខែ) ក្នុងម្នាក់។ ជាលទ្ធផលមកដល់បច្ចុប្បន្ននេះ មានយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យចំនួន ៧៣ ៧៨៧នាក់ បានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីសិក្សាចំនួន ៧៨៦ថ្នាក់ លើមុខជំនាញចំនួន ៤៥ ដែលក្នុងនោះមាន៖

១. កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ សរុបចំនួន ២០ ៧៩១នាក់(កម្មវិធីទូទៅចំនួន ៤១០នាក់ និងកម្មវិធី ១,៥លាន ចំនួន ២០ ៣៨១ នាក់)
២. កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ ចំនួន ២ ៦៤៦នាក់
៣. កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ចំនួន ១ ៦៦៤នាក់
៤. កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសចំនួន ១៦ ៥៥១នាក់
៥. កម្រិតបរិញ្ញាបត្របច្ចេកទេសចំនួន ២៨ ៤០២នាក់។

### ៣.៣. ពង្រឹងកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ និងងាយរងហានិភ័យ

ចំពោះការធ្វើស្ពាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានគ្រោះអាសន្ន រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចន្លោះពីចុងខែមិថុនា ឆ្នាំ២០២០ រហូតដល់ចុងខែមេសា ឆ្នាំ២០២៤ ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ដូចជា គ្រួសារមានបណ្ណសមធម៌ប្រភេទ១



ប្រភេទ២ និងសមាជិកគ្រួសារជាមនុស្សចាស់ អាយុ ៦០ឆ្នាំឡើងទៅ ជនមានពិការភាព អ្នកមានផ្ទុកមេរោគអេដស៍ និងកុមារអាយុក្រោម ៥ឆ្នាំ សរុបចំនួន ៧១៤ ១៥២គ្រួសារ ដោយចំណាយថវិកាចំនួនជាង ៥ ៤៣៨ប៊ីលានរៀល ស្មើនឹង ១ ៣៥៩.៦២លានដុល្លារ។

បន្ថែមលើនេះ ចាប់តាំងពីខែមេសា ឆ្នាំ ២០២៤មក រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដើម្បីលើកកម្ពស់សុខុមាលភាពដល់គ្រួសារក្រីក្រដែលមានបណ្ណសមធម៌ និងសមាជិកគ្រួសារជាជនងាយរងគ្រោះ ។ ចាប់តាំងពីការចាប់ផ្តើមដំណើរការកម្មវិធីនេះ រហូតដល់ចុងខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមគោលដៅដែលរួមមាន ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ ជនមានពិការភាព ជនចាស់ជរា និងអ្នកមានផ្ទុកមេរោគអេដស៍ សរុបចំនួន ៦២៦ ៨៥៩គ្រួសារ បានទទួលការឧបត្ថម្ភសាច់ប្រាក់ក្នុងទំហំថវិកាប្រមាណជាង ២១៦ប៊ីលានរៀល ស្មើនឹង ៤៥,៣៤លានដុល្លារ ។ រហូតមកដល់ ឆ្នាំ២០២៤ នេះ កម្មវិធីជាតិជំនួយសង្គមមានចំនួន ៨ ដែលមានវិសាលភាពគ្របដណ្តប់លើពលរដ្ឋសរុបចំនួន ១,២ លានគ្រួសារ ដែលមានសមាជិកចំនួនជាង ៤,៨លាននាក់ ស្មើនឹងប្រមាណ ២៨% នៃពលរដ្ឋសរុប ដោយចំណាយថវិកាជាតិបានកើនឡើងដល់ ១ ១៣៩,៧ ប៊ីលានរៀល ឬ ស្មើនឹង ២៨៥លានដុល្លារ សម្រាប់ឆ្នាំ២០២៤ ។

### ៣.៤. យុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ

ការដាក់ឱ្យដំណើរការជាផ្លូវការ «ថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ» កាលពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០២៤ ឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការគាំទ្រដល់ប្រជាពលរដ្ឋដែលកំពុងប្រកបមុខរបរ ធ្វើការងារ និងមានអាជីវកម្មនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងការបង្កើតឱកាសអភិវឌ្ឍអាជីវកម្ម និងពង្រីកមុខរបរ ជាពិសេសធ្វើឱ្យកម្រិតជីវភាព និងសុខុមាលភាពរបស់ពួកគាត់កាន់តែល្អប្រសើរមួយកម្រិតទៀត។ តាមរយៈការដាក់ចេញយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបានផលប្រយោជន៍



ពីប្រព័ន្ធគាំពារសង្គមផ្លូវការ ឆ្នាំ២០២៣-២០២៨ រាជរដ្ឋាភិបាល តាមរយៈស្ថាប័នសហគ្រិនខ្មែរ (KE) បានផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងការគាំពារសង្គម ជូនអ្នកប្រកបមុខរបរ និងធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលសុទ្ធសឹងតែជាប្រជាពលរដ្ឋក្រីក្រសរុបចំនួនជាង ១៣០ ០០០ នាក់ ដោយឥតគិតថ្លៃ។ សម្រាប់សេដ្ឋកិច្ចក្នុងប្រព័ន្ធចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២៤ ចំនួនរោងចក្រ-សហគ្រាសដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កើនឡើងចំនួន ៤ ២៧៦ និងបង្កើតការងារបានចំនួន ១០៩ ២៧០នាក់បន្ថែម ធ្វើឱ្យរោងចក្រ-សហគ្រាស សរុបមានចំនួន ៤៥ ២៥១ ដែលមានកម្មករនិយោជិតសរុបចំនួន ១ ៨២៤ ២៩៩នាក់ ក្នុងនោះវិស័យកាត់ដេរមានចំនួន ១ ៦១៣ រោងចក្រ-សហគ្រាស (កម្មករសរុប ៩៥០ ៣៧៤នាក់) និងវិស័យក្រៅកាត់ដេរ មានចំនួន ៤៣ ៦៣៨ រោងចក្រ-សហគ្រាស (កម្មករសរុប ៨៧៣ ៩២៥នាក់)។

## ៣.៥. លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងការរក្សាលំនឹងតម្លៃកសិផល

ក្នុងបេសកកម្មលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ រាជរដ្ឋាភិបាលបន្តវេនដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសេនាធិការ បានផ្តល់ហិរញ្ញប្បទានចំនួនជិត ៤១០ ០០០លានរៀល ឬ ស្មើនឹង ១០០លានដុល្លារ សម្រាប់សកម្មភាព




បុរេសកម្ម និងអន្តរសកម្មដល់កសិករកម្ពុជា។ បន្ថែមលើនេះ ក្រុមការងារនៃក្រសួងបានចុះពន្យល់ផ្សព្វផ្សាយ ដោយផ្ទាល់ពីទស្សនទាន នៃសហគមន៍កសិកម្មទំនើបជូនដល់ប្រជាកសិករជាច្រើនម៉ឺននាក់នៅក្នុង ខេត្តចំនួន ១៥ នៅទូទាំងប្រទេស។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ នេះ មានសហគមន៍កសិកម្មទំនើបចំនួន ៩ ត្រូវបានរៀបចំបង្កើតឡើងនៅក្នុងខេត្តចំនួន ៦ លើមុខដំណាំយុទ្ធសាស្ត្រចំនួន ៤ប្រភេទ គឺ ស្រូវ បន្លែ ស្វាយចន្ទី និងម្រេច។ ក្រសួងកសិកម្មបានធ្វើការសម្របសម្រួលជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូមួយចំនួន និងស្វែងរកប្រាក់កម្ចីដើមទុនការប្រាក់ទាប និងមិនតម្រូវឱ្យមានវត្ថុបញ្ចាំ ដែលអនុញ្ញាតឱ្យកសិករជាសមាជិកអាចចូលរួមក្នុងផលិតកម្មកសិកម្មបាន ដោយមិនចាំបាច់ជាប់បំណុលធនាគារដោយផ្ទាល់។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ នេះ សហគមន៍កសិកម្មទំនើបចំនួន ៥ រួចមកហើយ ដែលទទួលបានប្រាក់កម្ចីពីធនាគាររីង និងធនាគារភិវឌ្ឍន៍ជនបទនិងកសិកម្ម(ARDB) សរុបជាទឹកប្រាក់ចំនួន

ប្រមាណ ៨៥៥ ០០០ដុល្លារ ក្នុងអត្រាការប្រាក់ ៧% ក្នុង ១ឆ្នាំ។

### ៣.៦. ការដាក់ពង្រាយអ្នកជំនាញបច្ចេកទេសកសិកម្មតាមឃុំ-សង្កាត់

ក្នុងដំណើរឆ្ពោះទៅសម្រេចឱ្យបានជោគជ័យនូវកម្មវិធីគោលនយោបាយអាទិភាពទី៦ ក្នុងការដាក់ពង្រាយអ្នកជំនាញបច្ចេកទេសកសិកម្មតាមឃុំ-សង្កាត់ ដើម្បីងាយស្រួលគាំទ្រផ្នែកបច្ចេកទេសដល់កសិករ រាជរដ្ឋាភិបាលដែលមានក្រសួងមុខងារសាធារណៈជាសេនាធិការបានធ្វើការប្រឡងជ្រើសរើសមន្ត្រីកសិកម្មឃុំចំនួនពីរលើក និងជ្រើសរើសបានចំនួន ១ ២៥០នាក់ ។ មន្ត្រីដែលប្រឡងជាប់ទាំងនោះ



ត្រូវបានដាក់ពង្រាយនៅតាមភូមិចំនួន ២ ៦៧៦ នៃឃុំគោលដៅចំនួន ២៤២ ក្នុងស្រុកចំនួន ៨៣ នៃខេត្តចំនួន១៧ និងនៅតាមឃុំអាទិភាពទាំងអស់ដែលនៅតាមបណ្តោយព្រំដែន ដើម្បីសម្របសម្រួលទីផ្សារស្រូវជូនដល់កសិករ និងចុះណែនាំបច្ចេកទេសកសិកម្ម ព្រមទាំងសម្របសម្រួលចងក្រងការសហការដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម។ ការប្រឡងជ្រើសរើសទាំងពីរលើកនេះ ទទួលបានការសាទរពីមហាជន កសិករ និងបញ្ញវន្តថា ដំណើរការប្រឡងបានធ្វើឡើងប្រកបដោយគុណធិបតេយ្យ តម្លាភាព យុត្តិធម៌ និងគុណភាព។

## ៤. វិធានការគន្លឹះទាំង៥

ក្នុងការជំរុញ និងពង្រឹងគុណភាពរដ្ឋបាលសាធារណៈ: រាជរដ្ឋាភិបាលដែលមានក្រសួងមុខងារ



សាធារណៈជាសេនាធិការ បានរៀបចំយន្តការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលក្រោមនិយាមថ្មីបានចំនួន ១៣ លើក ដោយមានបេក្ខជនរាប់ម៉ឺននាក់ចុះឈ្មោះចូលរួមប្រឡង និងទទួលបានការទទួលស្គាល់ពីសំណាក់មហាជនទូទៅថា ការប្រឡងបានប្រព្រឹត្តទៅប្រកបដោយគុណធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ក្រោមអភិក្រម "អ្នកចេះ ជាប់"។

ចំពោះកិច្ចការងារលើកកម្ពស់គុណភាពអប់រំ ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចធិបតី**

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានគន្លឹះសម្រាប់កិច្ចការងារកែទម្រង់វិស័យអប់រំ ពីកម្រិតមត្តេយ្យដល់មធ្យមសិក្សា ដោយផ្តោតជាពិសេសលើការពង្រឹងជំនាញទន់របស់សិស្ស ពង្រឹងអភិបាលកិច្ចសាលា សកម្មភាពក្រៅម៉ោងសិក្សា និងការចូលរួមពីសហគមន៍ ដោយបានជ្រើសរើសសាលារៀនគោលដៅចំនួន ៤២ កម្រិតបឋមសិក្សា នៅបណ្តារាជធានី/ខេត្តចំនួន ៩ (រាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ ព្រៃវែង កំពង់ចាម សៀមរាប កោះកុង កំពង់ស្ពឺ និងកំពង់ឆ្នាំង) សម្រាប់ការអនុវត្តជំហានដំបូងដោយផ្តោតលើកម្មវិធីក្រៅម៉ោងសិក្សាចំនួន ២ម៉ោងបន្ថែម រួមមាន វិន័យ សីលធម៌ ចរិយាធម៌ ការងារស្ម័គ្រចិត្ត/សហគមន៍ ការចូលរួមពីសហគមន៍ និងវត្តអារាម។ ក្នុងការអនុវត្តយុទ្ធសាស្ត្រ ផ្ការីក ក្រសួងបាននឹងពង្រីកសាលាបឋមសិក្សាគោលដៅប្រមាណ ១០០ សាលាបន្ថែមទៀត។ តាមរយៈការដាក់ឱ្យអនុវត្តសាកល្បងស្តង់ដាសាលារៀនគំរូក្នុងសាលាបឋមសិក្សាគោលដៅទាំង ៤២ និងសាលាជាប់ស្តង់ដាគំរូទាំង ១២០ ក្រសួងនឹងបង្កើតជាស្តង់ដាតែមួយដើម្បីអនុវត្តនៅទូទាំងប្រទេសចាប់ពីឆ្នាំសិក្សា ២០២៤-២០២៥ ។

**ការលើកកម្ពស់គុណភាពសេវាសុខាភិបាល**



តាមរយៈក្រសួងសុខាភិបាល មន្ទីរពេទ្យចំនួន ៣ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ រួមមាន មន្ទីរពេទ្យជាតិតេជោសន្តិភាព ក្នុងខណ្ឌព្រែកព្នៅ មន្ទីរពេទ្យតេជោសែនកោះធំ ខេត្តកណ្តាល និងបំពាក់ឧបករណ៍ដ៏ទំនើបនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប។ សម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុក ជំរុញឱ្យមានការបង្កើនបរិមាណនិងគុណភាពថ្នាំ និងបរិក្ខារពេទ្យ ការជំរុញសេវា ២៤ម៉ោងលើ២៤ម៉ោង និង ៧ថ្ងៃក្នុងមួយសប្តាហ៍ ការពង្រឹងក្រមសីលធម៌ និងការទទួលខុសត្រូវវិជ្ជាជីវៈរបស់បុគ្គលិកសុខាភិបាល និងគ្រូពេទ្យ ក៏ដូចជាការពង្រីកសមត្ថភាពក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈ។

**ការពង្រឹងគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព** ក្រសួងមហាផ្ទៃបានដាក់ចេញនូវបទបញ្ជាប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន តាមរយៈការធ្វើតេស្តមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងបានបណ្តេញចេញពីក្របខ័ណ្ឌចំពោះមន្ត្រីមួយចំនួន ដែលត្រូវបានរកឃើញលទ្ធផលតេស្តវិជ្ជមាន។ កម្លាំងសមត្ថកិច្ចក៏បានអនុវត្តយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ល្បែងស៊ីសងខុសច្បាប់



និងក្មេងទំនើងនៅក្នុងសហគមន៍មូលដ្ឋាន។ ដោយផ្អែកលើយុទ្ធសាស្ត្រឌីជីថលថ្មីនៃការប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងក៏បានបង្កើតវិធីសាស្ត្រថ្មីៗ ទាន់សម័យ និងមានប្រសិទ្ធភាពតាមរយៈការដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ App NoDrug ដោយធ្វើការអប់រំតាមប្រព័ន្ធឌីជីថល និងអនុញ្ញាតឱ្យពលរដ្ឋរាយការណ៍ពីករណីគ្រឿងញៀន តាម App ដែលផ្សារភ្ជាប់កាន់តែជិតស្និទ្ធរវាងអាជ្ញាធរ និងប្រជាពលរដ្ឋស្របតាមទស្សនវិស័យ «ចូលរួមទាំងអស់គ្នា ដើម្បីជីវិតនិងសហគមន៍គ្មានគ្រឿងញៀន»។

ក្នុងបេសកកម្មពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ក្រសួងយុត្តិធម៌ បានដាក់ចេញយុទ្ធនាការចំនួន ២៖ ១- យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និង ២-យុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ដោយផ្តោតអាទិភាពលើសំណុំរឿងអគ្រានុកូលដ្ឋាន សំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ និងសំណុំរឿងពាក់ព័ន្ធនឹងក្មេងទំនើង។ ជាលទ្ធផល ក្នុងរយៈពេល ៨ខែដំបូងនៃឆ្នាំ២០២៤ ក្រសួងបានជួយដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋបានចំនួន ១ ១៣២ សំណុំរឿង (ស្មើនឹង ៦២.១២% នៃចំនួនពាក្យបណ្តឹង ១ ៨២២ សំណុំរឿងសរុបដែលទទួលបាន)។




ក្រសួងក៏បានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.) ដោយបានរៀបចំរួចរាល់នូវលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដើម្បីធានានូវកិច្ចដំណើរការស្ថាប័ន និងកិច្ចដំណើរការសម្រុះសម្រួលដោះស្រាយវិវាទក្នុងក្របខ័ណ្ឌនៃ អ.ដ.ក. និងបានជ្រើសរើស បណ្តុះបណ្តាល និងផ្តល់នីតិសម្បទាដល់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទចំនួន ៨៦រូប និងបានចាប់ផ្តើមអនុវត្តគម្រោងសំខាន់ៗចំនួន ២ គឺគម្រោងឆ្ពោះទៅមូលដ្ឋាន និងគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិច និងតំបន់ដាច់ស្រយាល ដោយបានចុះទៅខេត្តបាត់ដំបង ខេត្តរតនគីរី និងខេត្តមណ្ឌលគិរី ហើយនឹងបន្តចុះតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស។

## ៥. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលបន្តវេនបានដាក់ចេញនូវគោលនយោបាយត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងមានចក្ខុវិស័យវែងឆ្ងាយច្បាស់លាស់ប្រកបដោយមហិច្ឆតាខ្ពស់ ដើម្បីបម្រើប្រទេសជាតិនិងប្រជាជន ជាអ្នកការពារធានាសន្តិភាព ស្ថិរភាពនយោបាយ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី ភាពសុខសាន្តរបស់ប្រជាជន និងធានាការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព ដោយមិនអនុញ្ញាតឱ្យមានជនឬក្រុមណាមកបំផ្លាញ

បានឡើយ។

គ្រាន់តែក្នុងរយៈពេលមួយខ្លី រាជរដ្ឋាភិបាលដឹកនាំដោយ **សម្តេចមហាបវរធិបតី** បានសម្រេចលទ្ធផលលេចធ្លោជាច្រើន ក្នុងការធ្វើកំណែទម្រង់លើវិស័យធំៗដូចជា រដ្ឋបាលសាធារណៈ សេដ្ឋកិច្ច សុខាភិបាល អប់រំ កសិកម្ម ព្រមទាំងលើកកម្ពស់ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ និងការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់អភិវឌ្ឍន៍លើគ្រប់វិស័យ។ ទាំងនេះ គឺស្តែងចេញយ៉ាងជាក់ច្បាស់អំពីការចូលរួមគាំទ្រយ៉ាងសកម្មពីប្រជាពលរដ្ឋទាំងអស់ លើគោលនយោបាយអាទិភាពទាំង ៦ និងអាទិភាពគន្លឹះទាំង ៥ នៃ "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី១ " រួមទាំងកិច្ចការងារការបរទេស និងទំនាក់ទំនងអន្តរជាតិយ៉ាងសកម្ម ដើម្បីកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ដែលជា "របៀបវារៈគោលនយោបាយ សង្គម-សេដ្ឋកិច្ច" ឱ្យទៅជាចលនារួមដ៏ខ្លាំងក្លាលើមាគ៌ាសុខសន្តិភាពដ៏រឹងមាំ និងការអភិវឌ្ឍដ៏រស់រវើកឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និងភាពថ្កើងថ្កានប្រកបដោយគុណធម៌ សំដៅបង្កើនឡើងនូវសមិទ្ធផលថ្មីៗទៀតលើគ្រប់វិស័យ និងកាន់តែធំធេងជូនជាតិ និងប្រជាជន ៕



អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

Royal Government Spokesperson Unit